ក

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រម


០៨-៦-២០១០ -ព្រះរាជក្រម នស/រកម/០៦១០/០០៨ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ៤៤៥៧


### ២. ព្រះរាជក្រឹត្យ


២៦-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៣១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ អស់លោក ជាកងកម្លាំងប្រដាប់អាវុធ ចំនួន ៥៤ រូប ៤៤៧០

០២-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៤៦៤ ស្តីពី ការកែសម្រួលមាត្រា ៣៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ៤៤៧៣

០៣-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៤៦៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ការពារជាតិ តាមលំដាប់ថ្នាក់ ចំពោះអង្គភាព នគរបាលជាតិ ចំណុះក្រសួងមហាផ្ទៃ ចំនួន ៥៩ អង្គភាព ៤៤៧៥

០៣-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៤៦៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម.លោកជំទាវ និង អស់លោក ចំនួន ០៧ រូប ៤៤៧៨

០៣-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៤៦៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និង អស់លោក ចំនួន ១០ រូប ៤៤៧៩

០៣-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៤៧១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះព្រះគ្រូ **និន ចន្ថា** និង ព្រះគ្រូ **សេខ សំបូរ** ៤៤៨០

០៣-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៤៧២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និង អស់លោក ចំនួន ៦៣ រូប ៤៤៨១

០៣-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៤៧៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និង លោកស្រី ចំនួន ០៣ រូប ៤៤៨៦

## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ

០៩-៦-២០១០ -អនុក្រឹត្យលេខ ៥៤ អនក្រ.បក ស្តីពី ការកែសម្រួលអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០០៧ ស្តីពីការធ្វើអនុបយោគទីតាំងកោះមួយចំនួន ក្នុងភូមិសាស្ត្រ ខេត្តព្រះសីហនុ និង ខេត្តកំពត ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៤៤៨៧

០៤-៦-២០១០ -អនុក្រឹត្យលេខ ៦១៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៤៨៩

០៤-៦-២០១០ -អនុក្រឹត្យលេខ ៦១៥ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤៤៩២

០៤-៦-២០១០ -អនុក្រឹត្យលេខ ៦១៦ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៤៤៩៣

០៤-៦-២០១០ -អនុក្រឹត្យលេខ ៦១៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៤៩៤

០៧-៦-២០១០ -អនុក្រឹត្យលេខ ៦១៨ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ៤៤៩៥

០៨-៦-២០១០ -អនុក្រឹត្យលេខ ៦១៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៤៩៧

០៨-៦-២០១០ -អនុក្រឹត្យលេខ ៦២០ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៤៤៩៨

០៨-៦-២០១០ -អនុក្រឹត្យលេខ ៦២១ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ៤៤៩៩

០៨-៦-២០១០ -អនុក្រឹត្យលេខ ៦២២ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៤៥០១

០៨-៦-២០១០ -អនុក្រឹត្យលេខ ៦២៣ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ៤៥០៣

០៨-៦-២០១០ -អនុក្រឹត្យលេខ ៦២៤ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៤៥០៥

០៩-៦-២០១០ -អនុក្រឹត្យលេខ ៦២៥ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៤៥០៧

០៩-៦-២០១០ -អនុក្រឹត្យលេខ ៦២៦ អនក្រ.តត ស្តីពី ការបញ្ចូលក្របខ័ណ្ឌ នាយទាហាន ៤៥១០

### ២_សេចក្តីសម្រេច

០៨-៦-២០១០ -សេចក្តីសម្រេចលេខ ២៨ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំ ទទួលធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំអន្តរជាតិ នៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ា លើកទី ១១ ឆ្នាំ ២០១១ នៅព្រះរាជាណាចក្រកម្ពុជា ៤៥១១

## III_ការងារបណ្តាក្រសួង

### ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៨-៥-២០១០ -ប្រកាសលេខ ៤២២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៤៥១៥

២៨-៥-២០១០ -ប្រកាសលេខ ៤២៣ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត បង្កើតសាខារោងចក្រ ផលិតសម្លៀកបំពាក់ ៤៥១៩

២៨-៥-២០១០ -ប្រកាសលេខ ៤២៤ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ធើរីង លីមីធីត បង្កើតសាខារោងចក្រ បោះពុម្ពសម្លៀកបំពាក់ ៤៥២៣

២៨-៥-២០១០ -ប្រកាសលេខ ៤២៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុនដាយរិក អ៊ិនធើល (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៤៥២៧

## ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៦៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន ខា ខ័ន ត្រេឌីង** ៤៥៣១

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៦៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីមសុធី ហេងហុង** ៤៥៣៣

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៧០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីមភេក ទិហ្វ៊ីដ ខូ អិលធីឌី** ៤៥៣៥

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៧១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីភីអិម ត្រេឌីង** ៤៥៣៧

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៧២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី ឌីវេឡុបមេន អ៊ីមផត អិចផត** ៤៥៣៩

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៧៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេឡុន រូហ្សេ** ៤៥៤១

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៧៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ៃយេស៍ ហូលឌីង** ៤៥៤៣

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៨៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ែលគស៍ ហ្វេសិន ខមភេនី** ៤៥៤៥

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៨៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ូដីម** ៤៥៤៧

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៨៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី.ខេ.ធី** ៤៥៤៩

# ឃ


១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៨៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សៅវ៉ុស្គ អេស៊ា អ៊ិនធើណេសិនណល ត្រេឌីង** ៤៥៥១

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៩០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.អិន.អេច.ខបភើរេសិន** ៤៥៥៣

១០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣២៩១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល & អ ត្រេនស្ព័ត** ៤៥៥៥

# ព្រះរាជក្រម

នស/រកម/០៦១០/០០៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# នីតិវិធីបណ្តឹងទាក់ទង
# នឹងឋានៈបុគ្គល

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** គោលដៅនៃច្បាប់នេះ

ច្បាប់នេះ មានគោលដៅបញ្ញត្តនូវករណីពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

**មាត្រា ២.-** គោលបំណងនៃច្បាប់នេះ

ច្បាប់នេះ មានគោលបំណងធានាការអនុវត្តឱ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

**មាត្រា ៣.-** វិសាលភាពនៃច្បាប់នេះ

ច្បាប់នេះ មានវិសាលភាពអនុវត្តលើបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរួមមានបណ្តឹងដូចខាងក្រោមនេះ ៖

ក- បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ តាមបញ្ញត្តិនៃមាត្រា ៩៥៨ (មោឃភាពនៃអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី ។

ខ- បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ តាមបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ ដោយការឆបោក ឬការគំរាម) នៃក្រមរដ្ឋប្បវេណី ។

គ- បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ។

ឃ- បណ្តឹងបដិសេធបិតុភាព តាមបញ្ញត្តិនៃមាត្រា ៩៩០ (បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក) និងមាត្រា៩៩១ (បណ្តឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី ។

ង-បណ្តឹងទាមទារឱ្យទទួលស្គាល់ តាមបញ្ញត្តិនៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី ។

ច- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព តាមបញ្ញត្តិនៃមាត្រា ១០០២ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព) នៃក្រមរដ្ឋប្បវេណី ។

ឆ- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព តាមបញ្ញត្តិនៃមាត្រា ១០០៤ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីកូន) និង មាត្រា ១០០៥ (បណ្តឹងទាមទារឱ្យបញ្ជាក់

អំពីអត្ថិភាពនៃមាតុភាពពីម្ដាយ) នៃក្រមរដ្ឋប្បវេណី ។

ជ- បណ្ដឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា១០១៦ (ការកាត់កាល់នៃស្មុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី ។

ឈ- បណ្ដឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា ១០៣១ (មូលហេតុនៃការកាត់កាល់) នៃក្រមរដ្ឋប្បវេណី។

៣- បណ្ដឹងផ្សេងទៀតដែលមានគោលបំណងបង្កើត បញ្ជាក់អត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងនឹងឋានៈបុគ្គល។

## ជំពូកទី ២
## ការចូលរួមរបស់តំណាងអយ្យការ

**មាត្រា ៤.**_ ការអះអាងអង្គហេតុដោយតំណាងអយ្យការ ជាអាទិ៍

ចំពោះបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលតំណាងអយ្យការបានចូលរួមក្នុងនីតិវិធីតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៦ (ការចូលរួមរបស់តំណាងអយ្យការ) នៃក្រមនីតិវិធីរដ្ឋប្បវេណី តំណាងអយ្យការនោះ អាចធ្វើការអះអាងអង្គហេតុ ឬ អាចស្នើសុំឱ្យពិនិត្យភស្តុតាងបាន ។

## ជំពូកទី ៣
## តុលាការ

**មាត្រា ៥.**_ សមត្ថកិច្ច

១- បណ្ដឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងនឹងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្ដឹងនោះ ឬ លំនៅឋាននៅពេលដែលភាគីនោះទទួលមរណភាព ។

២- បើលំនៅឋានដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេ សមត្ថកិច្ចសាលាជម្រះក្ដីត្រូវកំណត់តាមទីសំណាក់ ។ បើពុំមានទីសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះ ត្រូវកំណត់តាមលំនៅឋានចុងក្រោយ ។

៣- ក្នុងករណីមិនអាចកំណត់តុលាការមានសមត្ថកិច្ច តាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ បណ្ដឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូងរាជធានីភ្នំពេញ ។

**មាត្រា ៦.-** ការផ្ទេរបណ្តឹងដើម្បីចៀសវាងការយឺតយ៉ាវ

ទោះបីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលណាមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ដើម្បីចៀសវាងការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីធ្វើឱ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគី និង សាក្សីដែលត្រូវសាកសួរ និង កាលៈទេសៈផ្សេងៗ តុលាការនោះអាចផ្ទេរបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទាំងមូល ឬ ផ្នែកណាមួយ ទៅតុលាការផ្សេងទៀតដែលមានសមត្ថកិច្ចបានតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

## ជំពូកទី ៤
## ភាគី

**មាត្រា ៧.-** ចុងចម្លើយ

១- ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានធ្វើឡើងដោយភាគីម្ខាងនៃទំនាក់ទំនងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនោះ ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ លើកលែងតែមានបញ្ញត្តិពិសេស ។

២- ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានធ្វើឡើងដោយជនដែលមិនមែនជាភាគីនៃទំនាក់ទំនងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនេះ ភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គលនេះ ត្រូវក្លាយជាចុងចម្លើយ ហើយនៅក្រោយពេលដែលភាគីណាមួយបានទទួលមរណភាព ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ លើកលែងតែមានបញ្ញត្តិពិសេស ។

៣- ក្នុងករណីដែលជនដែលត្រូវក្លាយជាចុងចម្លើយនៃបណ្តឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ទទួលមរណភាព ហើយគ្មានជនណាត្រូវក្លាយជាចុងចម្លើយទេនោះ តំណាងអយ្យការត្រូវក្លាយជាចុងចម្លើយ ។

**មាត្រា ៨.-** សមត្ថភាពក្នុងការធ្វើបណ្តឹង ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ជាអាទិ៍

១- ចំពោះសកម្មភាពបណ្តឹងក្នុងនីតិវិធីបណ្តឹងនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បញ្ញត្តិនៃមាត្រា ១៨ (សិទ្ធិលុបចោលសកម្មភាព) មាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមរដ្ឋប្បវេណី និង កថាខណ្ឌទី ៣ នៃមាត្រា ៣២ (សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្តឹង ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង) និង មាត្រា ៣៣ (បញ្ញត្តិពិសេសស្តីពីសកម្មភាពបណ្តឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ។

២- ក្នុងករណីជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង មានបំណងធ្វើសកម្មភាពបណ្តឹងដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចជ្រើសតាំងមេធាវីឱ្យធ្វើជាអ្នកតំណាងតាមពាក្យសុំបាន ។

៣- ទោះបីជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង មិនដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ក៏ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចបង្គាប់ឱ្យជ្រើសតាំងមេធាវីជាអ្នកតំណាង ឬ អាចជ្រើសតាំងមេធាវីជាអ្នកតំណាងដោយឆន្ទានុសិទ្ធិបាន ។

៤- ចំនួនទឹកប្រាក់នៃកម្រៃដែលជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង ត្រូវបង់ឱ្យមេធាវីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបានជ្រើសតាំងជាអ្នកតំណាង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី ៣ ខាងលើនេះ ត្រូវជាចំនួនទឹកប្រាក់ដែលតុលាការយល់ឃើញថាសមរម្យ ។

៥- ក្នុងចំណោមកម្រៃនិងសោហ៊ុយដែលបានបង់ឱ្យទៅមេធាវី ដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបានជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី៣ខាងលើនេះ ឬ បង់ឱ្យទៅមេធាវីដែលជនត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹងបានជ្រើសតាំង ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបង្គាប់ឱ្យជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ចំនួនទឹកប្រាក់ដែលតុលាការយល់ឃើញថាសមរម្យ ត្រូវក្លាយជាប្រាក់ប្រដាប់ក្តី ។

**មាត្រា ៩.-** សិទ្ធិអំណាចរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ជាអាទិ៍

១- ប្រសិនបើជនដែលត្រូវក្លាយជាដើមចោទ ឬ ចុងចម្លើយនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ជាជននៅក្រោមអាណាព្យាបាលទូទៅ អ្នកអាណាព្យាបាលទូទៅសម្រាប់ជននោះអាចប្តឹង ឬ អាចត្រូវបានប្តឹងដោយតំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅនោះបាន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកអាណាព្យាបាលទូទៅនោះ ជាភាគីម្ខាងទៀតនៃបណ្តឹងនោះ ។

២- ក្នុងករណីដែលកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅអាចប្តឹង ឬ អាចត្រូវបានប្តឹងដោយតំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅបាន ។

## ជំពូកទី ៥
## ប្រាក់ប្រដាប់ក្តី

**មាត្រា ១០.-** ប្រាក់ប្រដាប់ក្តី

ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលមានតំណាងអយ្យការជាភាគី ប្រាក់ប្រដាប់ក្តីដែលតំណាងអយ្យការ ត្រូវទទួលបន្ទុកដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺជាបន្ទុករបស់រដ្ឋ ។

Ksl

# ជំពូកទី ៦
# នីតិវិធីនៃបណ្តឹង

**មាត្រា ១១.-** ការរួមបញ្ចូលការទាមទារដែលពាក់ព័ន្ធ

ការទាមទារពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និង ការទាមទារពាក់ព័ន្ធនឹងសំណងការខូចខាតដែលកើតមានឡើងដោយអង្គហេតុដែលជាមូលហេតុនៃការទាមទារ ពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះ អាចធ្វើដោយបណ្តឹងតែមួយបាន ទោះបីមានបញ្ញត្តិមាត្រា ៧៧ (ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ។

**មាត្រា ១២.-** ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង និង បណ្តឹងតប

ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៤ នៃមាត្រា ៨៤ (ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង) កថាខណ្ឌទី ១ នៃមាត្រា ៨៦ (បណ្តឹងតប) និង មាត្រា ២៧៦ (ការដាក់ពាក្យបណ្តឹងតប) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ នៅក្នុងនីតិវិធីពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដើមចោទអាចបន្ថែម ឬ ផ្លាស់ប្តូរនូវការទាមទារ ឬ មូលហេតុនៃការទាមទារបាន ហើយចុងចម្លើយអាចប្តឹងតបបានរហូតដល់ពេលចប់ ការទាញហេតុផលដោយផ្ទាល់មាត់នៃការជម្រះក្តីលើកទី ១ ឬ ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ។

**មាត្រា ១៣.-** បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីដែលមិនត្រូវយកមកអនុវត្ត

១- មាត្រា ៩៤ (ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ) កថាខណ្ឌទី ១នៃមាត្រា ៩៦ (ការចាត់ទុកថាបានសារភាព) កថាខណ្ឌទី ២ នៃមាត្រា ១៤០ (ការសាកសួរសាមីភាគី) មាត្រា ១៥៣ (អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) កថាខណ្ឌទី ៤ នៃមាត្រា ១៥៦ (ការបញ្ជាក់ដោយប្រៀបធៀបអក្សរដែលសរសេរដោយដៃ) មាត្រា ២០០ (សាលក្រមកំបាំងមុខដើមចោទ) កថាខណ្ឌទី ២ នៃមាត្រា ២០១ (សាលក្រមកំបាំងមុខចុងចម្លើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងផ្នែកទាក់ទងនឹងអង្គហេតុដែលភាគីបានសារភាពចំពោះមុខតុលាការ នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៣ (គោលការណ៍សម្រេចសេចក្តីដោយកស្តុតាង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះនីតិវិធីបណ្តឹងនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

២- បញ្ញត្តិពីមាត្រា ២២០ (ការផ្សះផ្សាលើបណ្តឹង) ដល់មាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះកម្មវត្ថុនៃបណ្តឹង នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

**មាត្រា ១៤.-** ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ

នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគីមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន ។ ក្នុងករណីនេះ តុលាការត្រូវសួរមតិពីភាគីអំពីអង្គហេតុនោះ ។

**មាត្រា ១៥.-** ការបង្គាប់ឱ្យសាមីភាគីមកបង្ហាញខ្លួន ជាអាទិ៍

១- នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលសាកសួរសាមីភាគី តុលាការអាចបង្គាប់ឱ្យភាគីនោះមកបង្ហាញខ្លួនតាមកាលបរិច្ឆេទបាន ។

២- បញ្ញត្តិពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១៣២ (ករណីយកិច្ចរបស់សាក្សី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលភាគីដែលត្រូវបានបង្គាប់ឱ្យមកបង្ហាញខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ ។

**មាត្រា១៦.-** ការមិនធ្វើជាសាធារណៈនៃការទាញហេតុផលដោយផ្ទាល់មាត់

១- ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មិនត្រូវធ្វើជាសាធារណៈឡើយ ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏តុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដោយធ្វើជាសាធារណៈ ឬ អាចអនុញ្ញាតឱ្យជនណាដែលតុលាការយល់ឃើញថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បានដែរ ។

**មាត្រា ១៧.-** វិសាលភាពនៃបុគ្គលដែលទទួលនូវអានុភាពនៃសាលក្រម ឬ សាលដីកាស្ថាពរ

១- ទោះបីជាមានបញ្ញត្តិនៃមាត្រា ១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលមានអានុភាពចំពោះតតិយជនដែរ ។

២-ក្នុងករណីដែលមានការទាមទារឱ្យលុបចោលនូវអាពាហ៍ពិពាហ៍ដោយយកមូលហេតុផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៤៩ (ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព) នៃក្រមរដ្ឋប្បវេណី ហើយបើការទាមទារនេះត្រូវបានច្រានចោល ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរដែលច្រានចោលការទាមទារនោះ មានអានុភាពចំពោះសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុន លុះត្រាតែសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុននោះ បានចូលរួមអន្តរាគមន៍ក្នុងបណ្តឹងដែលពាក់ព័ន្ធនឹងការទាមទារនោះ ដោយយោងតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**មាត្រា ១៨._** ការហាមមិនឱ្យដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលក្រោយពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ

១- ក្រោយពេលសាលក្រម ឬ សាលដីកានៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានចូលជាស្ថាពរ ដើមចោទមិនអាចដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលស្តីពីទំនាក់ទំនងឋានៈបុគ្គលដដែល ដោយផ្អែកលើអង្គហេតុដែលខ្លួនអាចអះអាងបាន ដោយការបន្ថែម ឬ ការផ្លាស់ប្តូរនូវការទាមទារ ឬ មូលហេតុនៃការទាមទារ ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះបានឡើយ ។

២- ក្រោយពេលសាលក្រម ឬ សាលដីកានៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានចូលជាស្ថាពរ ចុងចម្លើយមិនអាចដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលស្តីពីទំនាក់ទំនងឋានៈបុគ្គលដដែលដោយផ្អែកលើអង្គហេតុដែលខ្លួនអាចអះអាងបាន ដោយការដាក់ពាក្យបណ្តឹងតបក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះបានឡើយ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសាលក្រម ឬ សាលដីកាដែលបានលើកបណ្តឹងចោលដោយហេតុថាបណ្តឹងនោះមានលក្ខណៈផ្ទុយនឹងច្បាប់ ។

**មាត្រា ១៩._** មរណភាពរបស់ដើមចោទ

ក្នុងករណីដែលដើមចោទនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទទួលមរណភាព នៅពេលដែលបណ្តឹងនោះកំពុងត្រូវបានចាត់ការ នោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះត្រូវចប់ដោយស្វ័យប្រវត្តិ លើកលែងតែករណីដែលមានបញ្ញត្តិពិសេស ។

**មាត្រា ២០._** មរណភាពរបស់ចុងចម្លើយ

១- ក្នុងករណីដែលភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គល ត្រូវក្លាយជាចុងចម្លើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៧ (ចុងចម្លើយ) នៃច្បាប់នេះ ហើយប្រសិនបើភាគីណាមួយទទួលមរណភាព បណ្តឹងនេះត្រូវបន្តនីតិវិធី ដោយយកភាគីម្នាក់ទៀតនោះមកធ្វើជាចុងចម្លើយ ។ ក្នុងករណីនេះ បញ្ញត្តិនៃចំណុច ក កថាខណ្ឌទី ១ នៃមាត្រា ១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តឡើយ ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នៃមាត្រា ៧ (ចុងចម្លើយ) នៃច្បាប់នេះ ហើយប្រសិនបើចុងចម្លើយទាំងអស់ទទួលមរណភាព បណ្តឹងនេះត្រូវបន្តនីតិវិធី ដោយយកតំណាងអយ្យការមកធ្វើជាចុងចម្លើយ ។

៣- ក្នុងករណីដែលចុងចម្លើយនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលមានគោលបំណងលែងលះគ្នា ឬ កាត់កាល់ ទទួលមរណភាព នៅពេលដែលបណ្តឹងនេះកំពុងត្រូវបានចាត់ការបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនេះត្រូវចប់ដោយស្វ័យប្រវត្តិ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ។

## ជំពូកទី ៧
## ការចាត់ចែងរក្សាការពារ

**មាត្រា ២១.-** ការចាត់ចែងរក្សាការពារ

១- ក្នុងករណីដែលមានពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចបង្គាប់ឱ្យធ្វើការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន ឬ ការរក្សាការពារផ្សេងទៀតដែលចាំបាច់ ដែលកំណត់ក្នុងគន្ថីទី ៧ (ការចាត់ចែងរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយឆន្ទានុសិទ្ធិបាន ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៣២ (ស្ថាប័នចាត់ចែងរក្សាការពារជាបណ្តោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ។

២- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីនៃមាត្រា ៥៥៨ (ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្តូរស្ថានភាព) និង មាត្រា ៥៥៩ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារស្ថានភាពពិសេស) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ជំពូកទី ៨
## ករណីពិសេសនៃបណ្តឹងស្តីពីទំនាក់ទំនងអាពាហ៍ពិពាហ៍

**មាត្រា ២២.-** សេចក្តីសម្រេចស្តីពីការចាត់ចែងបន្ទាប់បន្សំ ជាអាទិ៍

១-ប្រសិនបើតុលាការចេញសាលក្រម ឬ សាលដីកាដែលទទួលស្គាល់ការទាមទាររបស់ដើមចោទនៅក្នុងបណ្តឹងទាមទារលុបចោលនូវចំណងអាពាហ៍ពិពាហ៍ ឬ លែងលះគ្នា តុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ ហើយបើមានពាក្យសុំរបស់ភាគី ត្រូវធ្វើការសម្រេចសេចក្តីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬ ការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ។

២-ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ តុលាការអាចបង្គាប់ឱ្យភាគីប្រគល់កូន ឬ បង់ប្រាក់ ឬ ផ្តល់តាវកាលិកផ្សេងទៀត ក្នុងសាលក្រម ឬ សាលដីកា ដែលកំណត់ក្នុងកថាខណ្ឌទី ១ នោះបាន។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១៨២ (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម) នៃក្រមនីតិ-វិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះការសម្រេចសេចក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ។

៤-នៅពេលដែលតុលាការធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា ឬ ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ យោបល់របស់កូនត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងសមស្របទៅតាមអាយុ និង សភាពចាស់ទុំរបស់កូននោះ ។

**មាត្រា២៣.-** ដីកាសម្រេចបង្គាប់ឱ្យអនុវត្ត

១-ក្នុងករណីដែលមានបុគ្គលណាធ្វេសប្រហែសមិនអនុវត្តនូវករណីយកិច្ចដែលមានគោលបំណងឱ្យបង់ប្រាក់ ឬ ឱ្យផ្តល់តាវកាលិកនូវទ្រព្យសម្បត្តិផ្សេង ដែលកំណត់ដោយសេចក្តីសម្រេច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២២ (សេចក្តីសម្រេចស្តីពីការចាត់ចែងបន្ទាប់បន្សំ ជាអាទិ៍) ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យ តុលាការដែលបានធ្វើការសម្រេចសេចក្តីនេះ អាចចេញដីកាសម្រេចបង្គាប់ឱ្យអ្នកមានករណីយកិច្ច អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យមួយតាមពាក្យសុំរបស់អ្នកមានសិទ្ធិបាន ។

២- ដើម្បីបង្គាប់ឱ្យអនុវត្តករណីយកិច្ច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវស្តាប់សេចក្តីថ្លែងការណ៍របស់អ្នកមានករណីយកិច្ចនោះ ។

៣- ប្រសិនបើបុគ្គលដែលត្រូវបានបង្គាប់ឱ្យអនុវត្តករណីយកិច្ច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានធ្វើតាមការបង្គាប់នោះដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការដែលបានបង្គាប់ឱ្យអនុវត្តករណីយកិច្ចនោះ អាចបង្គាប់ឱ្យពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល ដោយដីកាសម្រេចបាន ។

៤- ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

## ជំពូកទី ៩
## ករណីពិសេសនៃបណ្តឹងអំពីទំនាក់ទំនងឪពុកម្តាយ និង កូន (បុត្តភាព)

**មាត្រា ២៤.-** ភាគីនៃបណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក ជាអាទិ៍

១- ក្នុងករណីដែលជនដែលត្រូវបានសន្មតថាជាឪពុក បានទទួលមរណភាពមុនកំណើតរបស់កូន ឬ ក្នុងករណីដែលជននោះបានទទួលមរណភាពក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៩៩០ (បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក) នៃក្រមរដ្ឋប្បវេណី ដោយមិនបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ជនដែលត្រូវបានបំពានសិទ្ធិសន្តតិកម្មដោយសារកូននោះ ឬ ញាតិលោហិតផ្សេងទៀត ក្នុង ៣ (បី) ថ្នាក់របស់ជនដែលត្រូវបានសន្មតថាជាឪពុកអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបាន ។ ក្នុងករណីនេះ ត្រូវដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលជនត្រូវបានសន្មតថាជាឪពុកនោះបានទទួលមរណភាព ។

២- ក្នុងករណីដែលជនដែលបានត្រូវសន្មតថាជាឪពុក បានទទួលមរណភាពក្រោយពេលបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ជនដែលអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចទទួលបន្តនូវនីតិវិធីនៃបណ្តឹងនោះបាន ក្នុងអំឡុងពេល ១ (មួយ)ឆ្នាំ គិតពីថ្ងៃដែលជនដែលត្រូវបានសន្មតថាជាឪពុក បានទទួលមរណភាព ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា

ROYAUME DU CAMBODGE · PALAIS ROYAL

Ksl

១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

**មាត្រា ២៥.–** ភាគីនៃបណ្តឹងបដិសេធបិតុភាពពីកូន ជាអាទិ៍

១- ក្នុងករណីដែលកូនបានទទួលមរណភាព ដោយមិនបានដាក់ពាក្យបណ្តឹងបដិសេធនូវបិតុភាព មុននឹងក្លាយជានីតិជន ឬ ដោយមិនបានដាក់ពាក្យបណ្តឹង ក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៩៩១ (បណ្តឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី បច្ឆាញាតិផ្ទាល់របស់កូនដែលបានទទួលមរណភាពនោះ អាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបាន ។ ក្នុងករណីនេះត្រូវដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះបានទទួលមរណភាព ។

២- ក្នុងករណីដែលកូនបានទទួលមរណភាព ក្រោយពីបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាព បច្ឆាញាតិផ្ទាល់របស់កូនដែលទទួលមរណភាពនោះ អាចទទួលបន្តនូវនីតិវិធីបណ្តឹងនោះបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះបានទទួលមរណភាព ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

**មាត្រា ២៦.–** ភាគីនៃបណ្តឹងទាមទារឱ្យទទួលស្គាល់ ជាអាទិ៍

១- នៅក្នុងបណ្តឹងទាមទារឱ្យទទួលស្គាល់ កូនត្រូវដាក់ពាក្យបណ្តឹង ដោយយកឪពុកមកជាចុងចម្លើយ ។ ក្រោយមរណភាពរបស់ឪពុក ត្រូវយកតំណាងអយ្យការមកជាចុងចម្លើយ ។

២- ប្រសិនបើឪពុកដែលជាចុងចម្លើយ ទទួលមរណភាព នៅពេលដែលតុលាការកំពុងចាត់ការបណ្តឹងទាមទារឱ្យទទួលស្គាល់នោះ តំណាងអយ្យការត្រូវទទួលបន្តនូវនីតិវិធីបណ្តឹងនោះ ។

៣- ក្នុងករណីដែលកូនបានទទួលមរណភាព ក្រោយពីបានដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចទទួលបន្តនូវនីតិវិធីនៃបណ្តឹងនោះ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះទទួលមរណភាព ទោះបីអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ៣ ឬ កថាខណ្ឌទី ៥ នៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី បានកន្លងផុតក៏ដោយ ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១៧៣ (ការផ្អាកនិងការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**មាត្រា ២៧.–** គោលការណ៍នៃវិធានការអន្តរកាល

១- ច្បាប់នេះត្រូវអនុវត្តចំពោះរឿងក្តីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលពាក្យ បណ្តឹងត្រូវបាន

ROYAUME DU CAMBODGE SECRETARIAT DU PALAIS ROYAL

Ksl

ដាក់ក្រោយពេលដែលច្បាប់នេះត្រូវបានអនុវត្ត ។

២- ចំពោះរឿងក្តីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលពាក្យបណ្តឹងត្រូវបានដាក់មុនពេលដែលច្បាប់នេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ទោះបីមានបញ្ញត្តិស្តីពីការធ្វើវិសោធនកម្មនូវច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីក៏ដោយ ។

**មាត្រា ២៨.-** ការមិនអនុវត្តបញ្ញត្តិស្តីពីការហាមមិនឱ្យដាក់ពាក្យបណ្តឹងក្រោយពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ

បញ្ញត្តិនៃមាត្រា ១៨ (ការហាមមិនឱ្យដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលក្រោយពេលសាលក្រម ឬសាលដីកាចូលជាស្ថាពរ) នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាលក្រម ឬ សាលដីកានៃរឿងក្តីដែលពាក្យបណ្តឹងត្រូវបានដាក់មុនពេលដែលច្បាប់នេះត្រូវបានអនុវត្ត បានចូលជាស្ថាពរ ។

## ជំពូកទី ១១
## អវសានបញ្ញត្តិ

**មាត្រា ២៩.-** ការអនុវត្តច្បាប់នេះ

ច្បាប់នេះ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ។

**មាត្រា ៣០.-** អានុភាពនៃបញ្ញត្តិដែលមានភាពផ្ទុយពីច្បាប់នេះ

បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលច្បាប់នេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីថ្ងៃដែលច្បាប់នេះត្រូវបានអនុវត្ត។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី០៤ ខែមិថុនាឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៦១០.០០៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

លេខ: ៤៤០ ច.ល

ដើម្បីចម្លងចែក

អង្គ ខុឞ ខុឡ្យាន រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនគេន

13/132

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ក-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :-

ឧត្តមសេនីយ៍ត្រី ឈួរ ចំនួនឡឿន ០០០៨៦៥

ខ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-

១ វរសេនីយ៍ឯក ធន ធឿន ០០០៨៦៧
២ វរសេនីយ៍ឯក ម៉ូ សារ៉ែម ០០០៨៦៦
៣ វរសេនីយ៍ឯក នន្ទ រាសី ០០០៨៦៥
៤ វរសេនីយ៍ឯក យ៉ង់ ភួងម៉ារ៉ា ០០១២៣១
៥ វរសេនីយ៍ឯក គីម ថេន ០០៤៥៦២
៦ វរសេនីយ៍ឯក នឹម សំបូរ ០០២០៥៩
៧ វរសេនីយ៍ទោ នូរ សិរិទ្ធិ ០០៣១៩១
៨ វរសេនីយ៍ត្រី ឃុ សុផាន់ ០១០៣៥៨

គ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :-

១ វរសេនីយ៍ត្រី តន់ ថាន ០០០៨៦៧
២ វរសេនីយ៍ត្រី ហ៊ុយ អ៊ុំម៉ារ៉ា ០០៣៥១៥
៣ វរសេនីយ៍ត្រី ឈ៉ត ឈាន ០១០៣៩៩
៤ វរសេនីយ៍ត្រី អ៊ុំ សុភា ០១០៤០០
៥ វរសេនីយ៍ត្រី ភង សារឿន ០១៥៣៤៧
៦ វរសេនីយ៍ត្រី ឆេត សារី ០១០៤០៨
៧ វរសេនីយ៍ត្រី គៀក ម៉ុច ០១០៤១២

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ៨-វរសេនីយ៍ត្រី | នៅ | ពុំ | ០១៥៣៣៨ |
| ៩-វរសេនីយ៍ត្រី | ហែម | គង់ | ០៤០៨៦៥ |
| ១០-វរសេនីយ៍ត្រី | ជា | សារឹម | ០១៥៣៤៥ |
| ១១-វរសេនីយ៍ត្រី | ប៊ុល | សំហោត | ០១៥៣៦០ |
| ១២-វរសេនីយ៍ត្រី | ហួត | សារឹម | ០១០៤០២ |
| ១៣-វរសេនីយ៍ត្រី | ឆេង | សូល | ០១៥៣៥៨ |
| ១៤-វរសេនីយ៍ត្រី | អ៊ុន | សាខ៊ាន | ០១៥៣៧៨ |
| ១៥-វរសេនីយ៍ត្រី | កេត | យ៉េយ | ០១០៤០៦ |
| ១៦-វរសេនីយ៍ត្រី | ជិន | ថន | ០១៥៣៦៤ |
| ១៧-វរសេនីយ៍ត្រី | សំ | ចាន់ថន | ០១០៤១០ |
| ១៨-វរសេនីយ៍ត្រី | អ៊ុំ | សំអាត | ០១០៤១១ |
| ១៩-វរសេនីយ៍ត្រី | សេង | សាវឿន | ០១០៤១៣ |
| ២០-វរសេនីយ៍ត្រី | សូ | រដ្ឋា | ០១០៤១៤ |
| ២១-អនុសេនីយ៍ឯក | ជិន | សារូន | ០១៩៥៣៤ |
| ២២-អនុសេនីយ៍ឯក | ប៉ែន | ប៊ូ | ០១៥៣៦៨ |
| ២៣-អនុសេនីយ៍ឯក | ឆេព | បូរាណ | ០១៥៣៧២ |
| ២៤-អនុសេនីយ៍ឯក | គង់ | ស៊ុំណេត | ០១៥៣៣៨ |

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ:-

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ត្រី | ប្រាក់ | សុគន្ធ | ០១០៦៤៣ |
| ២-អនុសេនីយ៍ឯក | ប៊ិន | សំ | ០២៧៨៨១ |
| ៣-អនុសេនីយ៍ឯក | ស្រី | ម៉ាច | ០២៧៩៨១ |
| ៤-អនុសេនីយ៍ឯក | ម៉ៅ | ហេង | ០១៥៣៧៤ |
| ៥-អនុសេនីយ៍ឯក | កែវ | គីមលី | ០១៥៣៤៣ |
| ៦-អនុសេនីយ៍ឯក | គោគ | សុខា | ០៤៣៦១៥ |
| ៧-អនុសេនីយ៍ឯក | អោក | ស៊ីយ៉ុន | ០១៥៣៤៨ |
| ៨-អនុសេនីយ៍ឯក | ព្រហ្ម | ចាសនា | ០១៥៣៥២ |
| ៩-អនុសេនីយ៍ឯក | អ៊ុង | សំអុល | ០២៧៨៦៥ |
| ១០-អនុសេនីយ៍ឯក | អៀម | ចណ្ឌី | ០២៧៨៧៨ |
| ១១-អនុសេនីយ៍ឯក | ប៊ិន | ម៉ុនរិទ្ធ | ០២៧៨៧៩ |
| ១២-អនុសេនីយ៍ឯក | គីម | សារួន | ០២៧៨៦៧ |
| ១៣-អនុសេនីយ៍ឯក | ហង្ស | សារី | ០៤០៨៦៦ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | |
|---|---|---|---|
| ១៤ | អនុសេនីយ៍ឯក | ម៉ៅ អុន | ០១៥៣៦៧ |
| ១៥ | អនុសេនីយ៍ឯក | យ៉ឹម សារ៉ាត់ | ០១៥៣៦៨ |
| ១៦ | អនុសេនីយ៍ឯក | ប៊ុន ឡៀង | ០១៥៣៧១ |
| ១៧ | អនុសេនីយ៍ឯក | សូ សម្បត្តិ | ០១៥៣៦២ |
| ១៨ | អនុសេនីយ៍ឯក | គឹម សុផាត | ០១៥៣៦១ |
| ១៩ | អនុសេនីយ៍ឯក | ឈុំ សំអុល | ០១៥៣៥៩ |
| ២០ | អនុសេនីយ៍ឯក | លី ចាន់ភារិទ្ធ | ០២៧៨៦៨ |
| ២១ | អនុសេនីយ៍ឯក | ម្រេង សារិន | ០២៧៨៨៣ |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៤.១០០៥.៤៣៧

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០ លេខ: ៤១៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១០/៤៦៤

## ស្តីពី

## ការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក
## នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវឌ្ឍនា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## ត្រាស់បង្គាប់

**មាត្រាមួយ.—**

មាត្រា៣៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ត្រូវបានកែសម្រួលដូចខាងក្រោម :

**មាត្រា៣៥ថ្មី .—**

មន្ត្រីនគរបាលជាតិកម្ពុជាទាំងពីរភេទមានសិទ្ធិទទួលរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ។

ក្រសួងមហាផ្ទៃ ត្រូវបើកប្រាក់ឧបត្ថម្ភមួយលើកជូនដល់និវត្តជន និងជនបាត់បង់សមត្ថភាពការងារ បន្ទាប់មកត្រូវផ្ទេរទៅឲ្យក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ។

ការគ្រប់គ្រង ការបើកចែករបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ និងការបើករបបធានារ៉ាប់រងសង្គមសម្រាប់គ្រួសារក្រោយមរណភាពរបស់និវត្តជន ឬជនបាត់បង់សមត្ថភាពការងារ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រាពីរ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបី .—**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ,ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១០*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា *៣៩៧.១០០៦.៤៧០*

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**លេខ: ៤៧៩ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែ មិថុនា ឆ្នាំ២០១០

**អគ្គលេខាធិការគណៈរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

2/2

# ព្រះរាជក្រឹត្យ

នស/រកត/០៦១០/៤៦៧

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស ការពារជាតិ ថ្នាក់ មាស :

១ នាយកដ្ឋានបុគ្គលិក

២ នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គីភ័យ

៣ នាយកដ្ឋាននគរបាលការពារ

៤ នាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន

៥ នាយកដ្ឋានសណ្ដាប់ធ្នាប់

៦ នាយកដ្ឋាននគរបាលទេសចរណ៍

៧ នាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ

៨ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

៩ នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច

១០ នាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ដ្រ

១១ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

១២ នាយកដ្ឋានសន្ដិសុខផ្ទៃក្នុង

១៣ នាយកដ្ឋានអន្ដោប្រវេសន៍

១៤ នាយកដ្ឋានប្រឆាំងភេរវកម្ម

១៥ នាយកដ្ឋានអង្គរក្ស

១៦ នាយកដ្ឋានចារកម្ម

១៧ នាយកដ្ឋាននគរបាលអន្ដរជាតិ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១៨ មន្ទីរប្រឆាំងគ្រឿងញៀន
១៩ នាយកដ្ឋាននគរបាលព្រំដែនគោក
២០ នាយកដ្ឋាននគរបាលព្រំដែនទឹក
២១ នាយកដ្ឋានបច្ចេកទេសព្រំដែន
២២ នាយកដ្ឋានវិទ្យុទាក់ទង
២៣ នាយកដ្ឋានបំពាក់អគ្គិសនី
២៤ អង្គភាពអន្តរាគមន៍
២៥ អង្គភាពតម្រួតបទបញ្ជា
២៦ នាយកដ្ឋានរដ្ឋបាលទូទៅ
២៧ នាយកដ្ឋានសរុប-ផែនការ
២៨ នាយកដ្ឋានកិច្ចការបរទេស
២៩ ស្នងការហិរញ្ញកិច្ច និងភស្តុភារ
៣០ នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន
៣១ នាយកដ្ឋានសរុប-ស្ថិតិ នៃអគ្គលេខាធិការដ្ឋាន
៣២ នាយកដ្ឋានកិច្ចការរដ្ឋបាល នៃអគ្គលេខាធិការដ្ឋាន
៣៣ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
៣៤ ស្នងការដ្ឋាននគរបាលខេត្តកណ្តាល
៣៥ ស្នងការដ្ឋាននគរបាលខេត្តតាកែវ
៣៦ ស្នងការដ្ឋាននគរបាលខេត្តព្រៃវែង
៣៧ ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង
៣៨ ស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ
៣៩ ស្នងការដ្ឋាននគរបាលខេត្តកែប
៤០ ស្នងការដ្ឋាននគរបាលខេត្តកំពត
៤១ ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ
៤២ ស្នងការដ្ឋាននគរបាលខេត្តកោះកុង
៤៣ ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង
៤៤ ស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់
៤៥ ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង
៤៦ ស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន
៤៧ ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ
៤៨ ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
៤៩ ស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ



៨០ ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ

៨១ ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ

៨២ ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម

៨៣ ស្នងការដ្ឋាននគរបាលខេត្តក្រចេះ

៨៤ ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង

៨៥ ស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី

៨៦ ស្នងការដ្ឋាននគរបាលខេត្តរតនគិរី

**ខ-គ្រឿងឥស្សរិយយស ការពារជាតិ ថ្នាក់ ប្រាក់ ៖**

១ អធិការដ្ឋានអធិការកិច្ច កិច្ចការនគរបាល

២ អធិការដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវកិច្ចការនគរបាល

៣ នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*៣រល.១០០៦.៤៧៣*

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១០*

លេខៈ ៤៣៤ ទ.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

**យើង**

នស/រកត/០៦១០/៤៦៩

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**
**នូវ**

គ្រឿងឥស្សរិយយស ជូនមន្ត្រីរាជការ ចំនួន ០៧ រូប ដែលមានគុណបំណាច់ខ្ពស់ ក្នុងការចូលរួមជួយកសាង សាលារៀន ,
ស្នាក់ការឃុំ, អាគាររដ្ឋបាល និងសមិទ្ធផលនានា នៅក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ ៖

ក. គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :-
១ ឯកឧត្តម **អោយ ខន**
២ លោកជំទាវ **សាវ សែនចន្ទ អោយ ខន**

ខ. គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :-
១ ឯកឧត្តម **ឡាវ កាង**
២ លោក **ថោង សុខរិត្ន**
៣ លោក **ជឹក ភ្នូ**
៤ លោក **សរ័ន្ធ គុំ**

គ. គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :-
វរសេនីយ៍ឯក **ឃួន សំបូរ** ០២៩០៧០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១០*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ពរល.១០០៦.៤៧៤*

លេខៈ ៤៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១០/៤៦៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :-

១ ឧត្ដមសេនីយ៍ត្រី ហ៊ាង និន ០០០៣០៥
២ ឯកឧត្ដម ប្រាក់ ស៊ីហារ៉ា
៣ លោក សំ សំអាត
៤ លោក ខេង តេង
៥ លោក សន កុសល
៦ លោក សុខ ជន
៧ ឧកញ៉ា យឹម សុផាត

ខ.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-

១ លោក សូ ប៊ុនណារ៉ា
២ វរសេនីយ៍ទោ កែវ សុផល ០០៣១៩៣
៣ លោក ណោង នឿន

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣.ល.១០០៦.៤៧៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១០

លេខ: ៤៧៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១០/៤៧២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

ព្រះគ្រូ តិន ចន្ទា

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :

ព្រះគ្រូ សេង សំបូរ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣៧.១០០៦.៤៧៧ **នរោត្តម សីហមុនី**

លេខ: ៤២៦ ច.ល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១០*

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០[illegible] ខែមិថុនា ឆ្នាំ២០១០

អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល

ស៊ុន ជីនកេន

នស/រកត/០៦១០/៤៧២

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហរាស គម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

**នូវ**

គ្រឿងឥស្សរិយយស ជូន ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម ចំនួន ១០៣ រូប ៖

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍** ចំពោះ ៖-

| | | | | |
|---|---|---|---|---|
| ១ | ឯកឧត្តម | ញ៉ែម | សុខរ័ត្ន | |
| ២ | ឯកឧត្តម | ហ៊ុន | ម៉ាណែត | ០៣៣៨៨៣ |
| ៣ | លោក | ស | សេរីវិចិត្រ | |

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍** ចំពោះ ៖-

| | | | |
|---|---|---|---|
| ១ | ឯកឧត្តម | អ៊ឹង | អៀង |
| ២ | លោក | យ៉ិនទៀង | ពុទ្ធិរិទ្ធ |
| ៣ | លោក | យ៉ិនទៀង | ពុទ្ធិរ៉ា |

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា** ចំពោះ ៖-

| | | | |
|---|---|---|---|
| ១ | ឯកឧត្តម | សាមីឌី | ស៊ីវឡានា |
| ២ | លោក | គីម | ម៉ាក្សសី |

**ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា** ចំពោះ ៖-

| | | | |
|---|---|---|---|
| ១ | លោក | ឈួន | ចាន់ថន |
| ២ | ឯកឧត្តម | ទ្រី | ព្រាយ |

**ង-គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ** ចំពោះ ៖-

| | | | | |
|---|---|---|---|---|
| ១ | ឯកឧត្តម | មៀច | សុជាន់ណា | |
| ២ | លោក | ផាន់ | សាម៉ន | |
| ៣ | វរសេនីយ៍ត្រី | ស៊ុំ | បូរ៉ា | ០០៩០១០ |
| ៤ | វរសេនីយ៍ត្រី | អ៊ឹម | ប៊ុនធឿន | ១៦២០៦៤ |
| ៥ | វរសេនីយ៍ត្រី | យូ | សុវណ្ណ | ០២៧៤០៦ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | | |
|---|---|---|---|---|
| ៦ | វរសេនីយ៍ត្រី | អ៊ឹង | ផល្លីន | ០៤៩៨៧០ |
| ៧ | វរសេនីយ៍ត្រី | សំ | អុន | ០២២៣២៨ |
| ៨ | វរសេនីយ៍ត្រី | លឹម | ចុងអេង | ០២២៣២៨ |

**ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ** ចំពោះ :-

| | | | | |
|---|---|---|---|---|
| ១ | ឧត្តមសេនីយ៍ត្រី | ប៊ុត | សុភាព | ០០២២៤១ |
| ២ | ឧត្តមសេនីយ៍ត្រី | អន | សារិទ្ធ | ០០៣២៥០ |
| ៣ | វរសេនីយ៍ឯក | ហ៊ាន | សុខេន | ០០២២៨៨ |
| ៤ | វរសេនីយ៍ឯក | អ៊ឹង | ជមនោរ | ០០១១៨៩ |

**ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា** ចំពោះ :-

| | | | | |
|---|---|---|---|---|
| ១ | ឯកឧត្តម | តឹម | នាន | |
| ២ | លោក | សុខ | សាម៉ន | |
| ៣ | លោក | វេង | មុនី | |
| ៤ | វរសេនីយ៍ទោ | ជុយ | សីហា | ០៤៧០៨៣ |
| ៥ | វរសេនីយ៍ទោ | អ៊ុយ | សុធា | ០២៥៦៨៩ |
| ៦ | វរសេនីយ៍ទោ | ម៉ឹង | មករា | ០១១០៩១ |
| ៧ | វរសេនីយ៍ទោ | ហ៊ាង | សារិទ្ធ | ០៤៣៤៩៣ |
| ៨ | វរសេនីយ៍ទោ | អ៊ឹង | ឃុន | ០១៨៦២៥ |
| ៩ | វរសេនីយ៍ទោ | ឡុង | ណាលីន | ០៤៩៨៥៥ |
| ១០ | វរសេនីយ៍ទោ | អ៊ឹង | ផាន | ១៧៩៤៣៤ |
| ១១ | វរសេនីយ៍ទោ | ធៀម | ទេវរិទ្ធ | ០១៥២៩៧ |
| ១២ | វរសេនីយ៍ទោ | ម៉ៅ | ស៊ីវ៉ាត | ០០២៦៥៨ |
| ១៣ | វរសេនីយ៍ទោ | ម៉ិន | ឃុនឌី | ០១៩៧៨១ |
| ១៤ | វរសេនីយ៍ទោ | យិន | សុធី | ០២៥៦៧១ |
| ១៥ | វរសេនីយ៍ទោ | ស៊ឹម | ប៊ុនថន | ០១៧៦៦១ |
| ១៦ | វរសេនីយ៍ទោ | ម៉ី | វាសនា | ២៣២១៣៣ |

**ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ** ចំពោះ :-

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ត្រី | ម៉ែ | ស៊ីថន | ១៦២២៥៤ |
| ២ | វរសេនីយ៍ត្រី | លន់ | ច័ន្ទសីហា | ០៤៨២០៧ |

| | | | | |
|---|---|---|---|---|
| ៣ | វរសេនីយ៍ត្រី | ថន | ដារ៉ា | ០៤៧៨៥៨ |
| ៤ | វរសេនីយ៍ត្រី | ជា | ប៊ុនហួរ | ០៤៣៤៧១ |
| ៥ | វរសេនីយ៍ត្រី | ខាត់ | ដា | ១៥៧១៤៧ |

**ឈ. គ្រឿងឥស្សរិយយស មាសការពារជាតិ ចំពោះ :-**

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ត្រី | សរ | សុវង្ស | ០២១១០៨ |
| ២ | វរសេនីយ៍ត្រី | ជា | ប៊ុនថាច | ០៦៦១៥៧ |
| ៣ | អនុសេនីយ៍ឯក | ប៊ិន | ប៉ឿន | ១៧៩៥៨៣ |
| ៤ | អនុសេនីយ៍ឯក | លុក | សុផាត | ២០៤២៨៥ |
| ៥ | អនុសេនីយ៍ឯក | ស្រី | សុផាត | ១៣៩៥៦៤ |
| ៦ | អនុសេនីយ៍ឯក | សាន | សារ៉ុជ | ០៤៧៨៦២ |
| ៧ | អនុសេនីយ៍ឯក | ហង្ស | ហេម | ២០៥៥៦៥ |
| ៨ | អនុសេនីយ៍ទោ | អ៊ុម | វណ្ណារ័ត្ន | ០៥៦៣៣៣ |
| ៩ | អនុសេនីយ៍ទោ | ផៃ | ម៉ានួន | ០៥៦៣៦៧ |
| ១០ | អនុសេនីយ៍ឯក | ខឹម | សំខាន់ | ១០៨៤៧១ |
| ១១ | អនុសេនីយ៍ឯក | ភី | សំណាង | ១៤៧៤០០ |
| ១២ | អនុសេនីយ៍ឯក | ជេដ្ឋា | វិល័យ | ០១៣៦២៨ |
| ១៣ | ព្រិន្ទបាលឯក | កង | សុវណ្ណារ៉ា | ០៦៣៦៦១ |
| ១៤ | អនុសេនីយ៍ត្រី | វៃ | សុវណ្ណ | ២៣១៥៥៥ |
| ១៥ | ព្រិន្ទបាលឯក | វ៉ាន់ឌី | ភារម្យ | ១៤៦២៨៦ |
| ១៦ | អនុសេនីយ៍ទោ | ម៉ៅ | ស៊ីណាត | ០៣២៥៤៣ |

**ញ. គ្រឿងឥស្សរិយយស ប្រាក់ ការពារជាតិ ចំពោះ :-**

| | | | | |
|---|---|---|---|---|
| ១ | អនុសេនីយ៍ឯក | ខែម | សារ៉ា | ១៦២០២១ |
| ២ | អនុសេនីយ៍ឯក | វី | ម៉ឺង | ២៣២១១៤ |
| ៣ | អនុសេនីយ៍ឯក | ទិត្យ | វិបុល | ១៦០៦១២ |
| ៤ | អនុសេនីយ៍ឯក | សរ | សេរីវិចិត្រ | ០៥៥៥០ |
| ៥ | អនុសេនីយ៍ឯក | សែម | នោ | ២០៧៣៦៥ |
| ៦ | អនុសេនីយ៍ឯក | ហ៊ុន | ស៊ីណាត | ១០៦៣០៨ |

| | | | | |
|---|---|---|---|---|
| ៧ | អនុសេនីយ៍ទោ | ថុន | សុខហេង | ០៧៩១៦៩ |
| ៨ | អនុសេនីយ៍ត្រី | សៀម | ស៊ីហ៊ាត | ០៦៨៦៣៥ |
| ៩ | ព្រិន្ទបាលឯក | គៀន | នី | ០៧៩១៦៧ |
| ១០ | ព្រិន្ទបាលទោ | ឈុន | ឆន | ០៧៩១៧៧ |
| ១១ | អនុសេនីយ៍ទោ | ស៊ឹម | វុទ្ធី | ២៣២១៧០ |
| ១២ | អនុសេនីយ៍ទោ | យូ | សុគន្ធភក្តី | ០៤៨៤៩៦ |
| ១៣ | អនុសេនីយ៍ទោ | ទៀប | សារិទ្ធ | ១៣៤៩៥០ |
| ១៤ | អនុសេនីយ៍ទោ | នួរ | សារ៉ៃន | ០៦៨៦៧៤ |
| ១៥ | អនុសេនីយ៍ទោ | ជិន | វណ្ណា | ១៣៤១៧១ |
| ១៦ | អនុសេនីយ៍ត្រី | ចាប | ពុទ្ធឌីណា | ០៥៦៣៦៤ |
| ១៧ | អនុសេនីយ៍ត្រី | រស់ | វណ្ណនី | ២៣១៨០៣ |
| ១៨ | អនុសេនីយ៍ត្រី | ព្រួ | ស៊ីណា | ០៦៣៤៦១ |
| ១៩ | អនុសេនីយ៍ត្រី | ផុន | ផូរី | ២៣១៨៥០ |
| ២០ | អនុសេនីយ៍ត្រី | ហែន | វុទ្ធី | ០៥៦២៨៧ |
| ២១ | អនុសេនីយ៍ត្រី | ស៊ិន | សាក់ | ២៣១៨៧៦ |
| ២២ | អនុសេនីយ៍ត្រី | ពៅ | ពិសិដ្ឋ | ២៣២០៨៤ |
| ២៣ | អនុសេនីយ៍ត្រី | រ័ត្ន | ធីរ៉ា | ២៣១៩០៨ |
| ២៤ | អនុសេនីយ៍ត្រី | ប៉ក់ | ណារ៉ូន | ២០៤២៨៤ |
| ២៥ | នាយចំណង់ | ហែ | សម្ផស្ស | ២៣១៨៦៤ |
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ :** ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ឱ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង | ឋានន្តរស័ក្តិ និងថ្នាក់ | ថ្ងៃខែឆ្នាំ ចូលនិវត្តន៍ |
|---|---|---|---|---|---|---|
| **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | | | | | | |
| ១ | **ប៉ោ ឡៀង** | ប | ២៨-០៦-១៩៤៩ | ប្រធាននាយកដ្ឋាន | ក.២.៦ | ០១-១២-២០០៩ |
| ២ | **នេត គូម៉ារី** | ស | ១៩-០៤-១៩៤៩ | អគ្គនាយករង | ក.២.៧ | ០១-១២-២០០៩ |
| **ក្រសួងអភិវឌ្ឍន៍ជនបទ** | | | | | | |
| ១ | **ម៉ក់ សុភី** | ប | ១៥-០១-១៩៥០ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ក.២.៥ | ០១-០២-២០១០ |
| **ក្រសួងទេសចរណ៍** | | | | | | |
| ១ | **ប៉ាន់ ចំណាន** | ស | ២៦-០៤-១៩៥៤ | អនុប្រធាននាយកដ្ឋាន | ក.២.៣ | ០១-០៤-២០១០ |
| **ក្រសួងសាធារណការ និងដឹកជញ្ជូន** | | | | | | |
| ១ | **សួន វុត្ថា** | ប | ០៥-០៤-១៩៥០ | អនុប្រធានមន្ទីរ | ក.២.២ | ០១-០៥-២០១០ |
| **ក្រសួងយុត្តិធម៌** | | | | | | |
| ១ | **តុង ពាង** | ប | ០១-០៩-១៩៥០ | អគ្គនាយករង | ក.២.១ | ០១-១០-២០១០ |
| **ក្រសួងកិច្ចការនារី** | | | | | | |
| ១ | **យស សាខន** | ប | ១៧-០៧-១៩៥០ | អគ្គលេខាធិការរង | ក.២.៣ | ០១-០៨-២០១០ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧២៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី
## ការបញ្ចូលក្របខ័ណ្ឌ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទៈ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ៈ** ត្រូវបានបញ្ចូលក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនលោកវរសេនីយ៍ឯក **ចក់ ចិន្តា** អត្តលេខ ០០១០៦២ នាយទាហាន អគ្គបញ្ជាការដ្ឋាន ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនិងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៧ . សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួង**

**រៀបចំទទួលធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំអន្តរជាតិនៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ា**

**លើកទី ១១ ឆ្នាំ ២០១១ នៅព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី២៨ ខែឧសភាឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកម្ចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំទទួលធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំអន្តរជាតិនៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ា លើកទី ១១ ឆ្នាំ ២០១១ ដែលនឹងប្រព្រឹត្តធ្វើនៅព្រះរាជាណាចក្រកម្ពុជា ហៅកាត់ថា គណៈកម្មការកិច្ចប្រជុំលើកទី១១។ សមាសភាពនៃគណៈកម្មការកិច្ចប្រជុំលើកទី ១១ រួមមាន ៖

| | | |
|---|---|---|
| - ឯកឧត្តម ប្រាក់ សុខុន | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអនុប្រធានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន | ប្រធាន |
| - ឯកឧត្តម ជុំ ប៊ុន រ៉ុង | អគ្គលេខាធិការអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន | អនុប្រធាន |
| - ឯកឧត្តម ជា សុខុម | អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | អនុប្រធាន |
| - ឯកឧត្តម ហេង រតនា | អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា | អនុប្រធាន |
| - ឯកឧត្តម ព្រំ សុកមង្គល | អគ្គលេខាធិការរងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | អនុប្រធានប្រចាំការ |
| - ឯកឧត្តម សុន គន្ធរ | អគ្គលេខាធិការគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ | សមាជិក |
| - ឯកឧត្តម សម សុគ្គា | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - ឯកឧត្តម ប៊ុន សម | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| - ឯកឧត្តម គឹម ស៊ីថន | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| - ឯកឧត្តម សែម សុខា | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - ឯកឧត្តម សុខ ផេង | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| - ឯកឧត្តម អ៊ុក សុជាតិ | រដ្ឋលេខាធិការក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | សមាជិក |
| - ឯកឧត្តម ម៉ៅ ហាវណ្ណាល់ | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| - ឯកឧត្តម បួន លឹមហេង | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - ឯកឧត្តម សួន ឈាងលី | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| - ឯកឧត្តម យុន វុធ | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| - ឯកឧត្តម ហាក់ សឹងលី | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| - ឯកឧត្តម ហ៊ុយ សាវ៉ាវុធ | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| - ឯកឧត្តម ហោ សារុន | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| - ឯកឧត្តម ប៉ែន ស៊ីម៉ន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| - ឯកឧត្តម សែម សុវណ្ណនី | អគ្គនាយកមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីននិងកាកសំណល់សង្គ្រាម | សមាជិក |
| - ឯកឧត្តម គន្ធ សំអឿន | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |

| | | |
|---|---|---|
| - ឯកឧត្តម ប្រាក់ សិទ្ធិ | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| - ឯកឧត្តម ម៉ៅញ សំអាត | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាននាយកដ្ឋានពិធីការនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - លោក ទុយ រី | ប្រធាននាយកដ្ឋានអង្គការអន្តរជាតិក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - លោក នួន សុមេធ | នាយកខុទ្ទកាល័យសាលារាជធានីភ្នំពេញ | សមាជិក |

**ប្រការ ២.-**

គណៈកម្មការកិច្ចប្រជុំលើកទី១១នេះ មានភារកិច្ច និង ការទទួលខុសត្រូវដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពមេ ប្រតិទិនកិច្ចដំណើរការងារ និងតម្រូវការធនធានមនុស្ស សម្រាប់ការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃកិច្ចប្រជុំលើកទី១១។
- លើកយោបល់និងសំណើជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យនិងសម្រេចលើរាល់កិច្ចការពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃកិច្ចប្រជុំលើកទី១១។
- គ្រប់គ្រង សម្របសម្រួលសកម្មភាព និងបែងចែកភារកិច្ចការងារជូនទៅតាមសមត្ថកិច្ចរបស់ក្រសួងនិងស្ថាប័នពាក់ព័ន្ធនៅក្នុងដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃកិច្ចប្រជុំលើកទី១១ ឱ្យបានរលូន និងសម្រេចជោគជ័យ។
- លើកគម្រោងតម្រូវការថវិកាសម្រាប់ដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃកិច្ចប្រជុំលើកទី១១ និងសុំការអនុម័តពីរាជរដ្ឋាភិបាល ។
- កៀរគរវិភាគទានជាធនធាន ទាំងសម្ភារបច្ចេកទេស ទាំងថវិកាពីអន្តរជាតិ ជាតិ និងផ្នែកឯកជន ដើម្បីសម្រាលបន្ទុកចំណាយរបស់រាជរដ្ឋាភិបាល និង សម្របសម្រួលការចំណាយ និងប្រើប្រាស់ធនធានទាំងនោះ ដោយតម្លាភាព និងប្រសិទ្ធភាព។
- គ្រប់គ្រង ពិនិត្យ និងសម្រេចលើគម្រោងសំណើចំណាយថវិកាដែលជាធនធានរបស់រាជរដ្ឋាភិបាល និងសម្រេចលើសំណើទូទាត់ការចំណាយក្នុងការងាររៀបចំ និងការប្រព្រឹត្តទៅនៃកិច្ចប្រជុំ។
- ធ្វើទំនាក់ទំនងជាមួយមជ្ឈមណ្ឌលអន្តរជាតិសកម្មភាពមីនមនុស្សធម៌ក្រុងហ្សឺណែវ ដើម្បីសម្របសម្រួលការងារកិច្ចប្រជុំ និងការងារជាប្រធាននៃអង្គប្រជុំលើកទី ១១ ។
- រៀបចំ និងសម្របសម្រួលសកម្មភាពដទៃទៀត ដែលគាំទ្រដល់កិច្ចដំណើរការកិច្ចប្រជុំលើកទី ១១។
- ធ្វើរបាយការណ៍សកម្មភាពការងារ និងលទ្ធផលអង្គប្រជុំលើកទី ១១ ជូនរាជរដ្ឋាភិបាល។

**ប្រការ ៣.-**

គណៈកម្មការកិច្ចប្រជុំលើកទី ១១ អាចបង្កើតអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអនុវត្តការងារ។ គណៈកម្មការកិច្ចប្រជុំលើកទី ១១ មានលេខាធិការដ្ឋានមួយជាសេនាធិការដែលមានទីតាំងស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រី។ សមាសភាព និងតួនាទីភារកិច្ចរបស់អនុគណៈកម្មការជំនាញ និងលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការ។

**ប្រការ ៤.-**

អនុប្រធាន និងសមាជិកទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ គណៈកម្មការកិច្ចប្រជុំលើកទី ១១ អាចកោះអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមប្រជុំ ដោះស្រាយការងារ និងអាចស្នើសុំកិច្ចសហការទៅតាមតម្រូវការចាំបាច់។

**ប្រការ ៥.-**

គណៈកម្មការកិច្ចប្រជុំលើកទី១១ មានកញ្ចប់ថវិកាសម្រាប់ដំណើរការក្នុងកញ្ចប់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ៤២២ ឧ.រ.ថ.ក.ប (ឯក)

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ៩០៧ /៩៧ គ.វិ.ក ចុះថ្ងៃទី២០.០៥.១៩៩៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត ចុះថ្ងៃទី០៥.០៥. ២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឱ្យក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត តំណាងដោយលោក NG HUNG YAU សញ្ជាតិចិន អាយុ៥៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ KJ0083846 ចុះថ្ងៃទី០៧.០៤.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ HONG KONG, CHINA. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| សម្លៀកបំពាក់ | ៣២២០ |

-ផ្លាកឈ្មោះរោងចក្រ ៖ " *ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត (HUNG WAH (CAMBODIA) GARMENT MANUFACTURING LIMITED. )*"

-ទីតាំងរោងចក្រ ៖ " *ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ*"

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការ ចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** -ប្រកាសលេខ៦៧១ ប្រក.ផក ចុះថ្ងៃទី១៨.០៧.១៩៩៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ធឺរីង លីមីធីត (HUNG WAH (CAMBODIA) GARMENT MANUFACTURING LIMITED.) ដែលមានទីតាំងស្ថិតនៅ ភូមិត្រពាំងខ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៦:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនព្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤៩៣ ឧរថ.ក.១.ស្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ៦៣៨ /០៥ គ.វ.ក ចុះថ្ងៃទី២៥.០២.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត ចុះថ្ងៃទី០៥.០៥.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឱ្យក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត តំណាងដោយលោក NG HUNG YAU សញ្ជាតិចិន អាយុ៥៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ KJ0083846 ចុះថ្ងៃទី០៧.០៤.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ HONG KONG, CHINA. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតសាខារោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| សម្លៀកបំពាក់ | ៣២២០ |

-ផ្លាកឈ្មោះរោងចក្រ ៖ *" ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ធឺរីង លីមីធីត សាខាទី១ (HUNG WAH (CAMBODIA) GARMENT MANUFACTURING LIMITED BRANCH No1. )"*

-ទីតាំងរោងចក្រ ៖ *" ភូមិត្រពាំងវែក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ"*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង

និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការ ចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** -ប្រកាសលេខ៣៩៩ ឧរថ.កឧ.ប្រក. ចុះថ្ងៃទី០៨.០៥.២០០៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ហុងវ៉ាកម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត សាខាទី១ (HUNG WAH (CAMBODIA) GARMENT MANUFACTURING LIMITED BRANCH No1.) ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងរំចេក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៦:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ៤២៤ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ៧៥០ /១០ គ.វ.ក ចុះថ្ងៃទី០៩.០៤.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត ចុះថ្ងៃទី០៥.០៥.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត តំណាងដោយលោក NG HUNG YAU សញ្ជាតិចិន អាយុ៥៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ KJ0083846 ចុះថ្ងៃទី០៧.០៤.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ HONG KONG, CHINA. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតសាខារោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| បោះពុម្ពសម្លៀកបំពាក់ | ៣៤២០ |

២៥

-ផ្លាកឈ្មោះរោងចក្រ ៖ *"ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ធីរីង លីមីធីត សាខាទី២ (HUNG WAH (CAMBODIA) GARMENT MANUFAC- TURING LIMITED. BRANCH No2 )"*

-ទីតាំងរោងចក្រ ៖ *" ផ្លូវជាតិលេខ៤ ភូមិផ្សារកំបូល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល"*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាម់សេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង

និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការ ចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកណ្តាល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤២៥ ឧ.ស.ក/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ ៩០៣ /១០ គ.វ.ក ចុះថ្ងៃទី០៥.០៥.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ដាយរ៉ិក អ៊ិនធើល (ខេមបូឌា) ចុះថ្ងៃទី០៦.០៥.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ដាយរ៉ិក អ៊ិនធើល (ខេមបូឌា) តំណាងដោយ លោក HWANG SOON JUNG សញ្ជាតិកូរ៉េ អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ M27679972 ចុះថ្ងៃទី ១២.០៩.២០០៨ មានអាសយដ្ឋានបច្ចុប្បន្នៈ Floor 5, East Branch Bld, Chamber of Commerce497-66, Dapsipri-Dong, Dong Dae Moon-Gu Seoul, Korea ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| សម្លៀកបំពាក់ | ៣២២០ |

-ផ្លាកឈ្មោះរោងចក្រ ៖"ដាយរ៉ិក អ៊ិនធើល (ខេមបូឌា) ( DIRECT INT'L (CAMBODIA) CO., LTD.)"

-ទីតាំងរោងចក្រ ៖ *"ភូមិបន្ទាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ"*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មីនៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខ... រោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការ ចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬ ករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** -ប្រកាសលេខ២០០ ឧវថ.កឧ.ប្រក ចុះថ្ងៃទី២៨.០៣.២០០៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន អេស អ៊ីកែវីល (ACE APPAREL CO., LTD.) ដែលមានទីតាំងស្ថិតនៅ ភូមិបន្ទាស្អិត សង្កាត់ឃ្មួញ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៦:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលារាជធានីភ្នំពេញ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣២៦៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា ៖

